CITY OF LONG BEACH PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១ ខែមេសាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ក្រសួងសុខាភិបាលនិងសេវាប្រជាជននៃទីក្រុងឡុងប៊ិចបាន ចេញបញ្ជាឱ្យអ្នកដែលមានជម្ងឺ COVID-19 នៅដាច់ដោយឯង

## អ្នកដែលស្ថិតក្នុងហានិភ័យនៃការឆ្លងជម្ងឺ COVID-19 ត្រូវនៅដាច់ពីអ្នកដទៃ

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះក្រសួងសុខាភិបាលនិងសេវាប្រជាជនបានប្រកាសបទបញ្ជាថ្មីចំនួន ២ ដែល តម្រូវឲ្យបុគ្គលដែលមានជម្ងឺ COVID-19 នៅដាច់ដោយឯងហើយអ្នកដែលប្រឈមនឹងហានិភ័យនៃការឆ្លងជម្ងឺ COVID-19 ឱ្យនៅដាច់ពីអ្នកដទៃដើម្បីកាត់បន្ថយការរាលដាលនៃជម្ងឺ COVID-19 នៅក្នុងទីក្រុងឡុងប៊ិច។ បទបញ្ជាសុខភាពថ្មីទាំងនេះនឹងត្រូវអនុវត្តភ្លាមៗហើយនឹងបន្តរហូតដល់មានការជូនដំណឹងបន្ថែម។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ការរីករាលដាលនៃជម្ងឺ COVID-19 កំពុងបង្កើតអោយមានហានិភ័យសុខភាពសាធារណៈកើនឡើងយ៉ាងខ្លាំងដល់សហគមន៍ឡុងប៊ិច។ បទបញ្ជាទាំងនេះគឺចាំបាច់ដើម្បីការពារប្រជាជនងាយរងគ្រោះនិងជួយបន្ថយការរាលដាលនៃជម្ងឺ COVID-19។"

អ្នកជំនាញសុខភាពសាធារណៈប្រើការដាក់ឱ្យនៅដាច់ពីអ្នកដទៃដើម្បីញែកបុគ្គលដែលអាចមានការប៉ះពាល់នឹង

មេរោគពីសាធារណជនក្នុងករណីដែលបុគ្គលនោះអាចឆ្លងជម្ងឺហើយចម្លងដល់អ្នកដទៃ។ ប្រជាជនដែលត្រូវចាត់ឱ្យនៅដាច់ពីអ្នកដទៃគឺត្រូវបញ្ជាឱ្យស្នាក់នៅផ្ទះនិងកំណត់រាល់ចលនាដែលអាចឱ្យពួកគាត់នៅជិតមនុស្សផ្សេងទៀតក្នុងរយៈពេល ១៤ ថ្ងៃ។ ប្រសិនបើពួកគាត់ចាប់ផ្តើមបង្ហាញរោគសញ្ញាពួកគាត់អាចត្រូវបានតម្រូវឱ្យញែកដាច់ដោយឯង។ ការញែកដាច់ដោយឯងគឺពេលដែលបុគ្គលឈឺត្រូវញែកខ្លួនពីមនុស្សគ្រប់រូបសូម្បីតែសមាជិកគ្រួសារផ្ទាល់របស់គាត់ដើម្បីការពារការរាលដាលនៃមេរោគទៅអ្នកដទៃ។

ដើម្បីកាត់បន្ថយចំនួនអ្នកដែលប្រឈមនឹងជម្ងឺ COVID-19 អ្នករស់នៅទីក្រុងឡុងប៊ិចទាំងអស់ត្រូវគោរពតាមបទបញ្ជាដូចខាងក្រោម៖

**ការឱ្យនៅដាច់ដោយឯង៖**
អ្នកដែលមានឬទំនងជាមានជម្ងឺ COVID-19 គឺត្រូវឱ្យនៅដាច់ដោយឯងយ៉ាងហោចណាស់ ៧ ថ្ងៃបន្ទាប់ពីរោគសញ្ញាបានចាប់ផ្តើមមានហើយរយៈពេលយ៉ាងតិច ៧២ ម៉ោងបានកន្លងផុតទៅចាប់តាំងពីរោគសញ្ញាបានបាត់។ បុគ្គលនោះត្រូវតែញែកខ្លួនឯងក្នុងរយៈពេលដែលតម្រូវតាមករណីណាមួយដែលកើតក្រោយ។

មនុស្សគ្រប់រូបដែលត្រូវបានតម្រូវឱ្យនៅដាច់ដោយឯង<u>មិនអាច</u>ចាកចេញពីកន្លែងស្នាក់នៅឬចូលកន្លែងសាធារណៈឬឯកជនផ្សេងទៀតបានទេលើកលែងតែដើម្បីទទួលការព្យាបាលចាំបាច់។ លើសពីនេះទៅទៀតអ្នកដែលត្រូវបានតម្រូវឱ្យនៅដាច់ដោយឯងត្រូវតែជូនដំណឹងដល់មនុស្សជិតស្និទ្ធឱ្យបានដឹងថាពួកគាត់អាចមានការប៉ះពាល់នឹងមេរោគដែរហើយដូច្នេះពួកគាត់ត្រូវនៅដាច់ពីអ្នកដទៃ។

ចំពោះបទបញ្ជាឱ្យនៅដាច់ដោយឯងអ្នកដែលកំណត់ថាមានឬទំនងជាមានជម្ងឺ COVID-19 គឺជាបុគ្គលដែលមាន៖

- លទ្ធផលតេស្តវិជ្ជមានសម្រាប់ COVID-19
- អាការៈនិងរោគសញ្ញាដែលត្រូវនឹងជម្ងឺ COVID-19 ក្នុងរយៈពេល ១៤ ថ្ងៃបន្ទាប់ពីមានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សដែលធ្លាប់មានឬត្រូវបានជឿថាមានជម្ងឺ COVID-19។ ឬ
- គ្រូពេទ្យបានជម្រាបគាត់ថាគាត់ទំនងជាមានជម្ងឺ COVID-19។

បុគ្គលគ្រប់រូបដែលមានលក្ខណៈដូចខាងលើត្រូវតែប្រកាន់ខ្ជាប់នូវតម្រូវការដែលមានចែងក្នុងសេចក្តីណែនាំអំពីការញែកខ្លួនដាច់ដោយឯងដោយនៅផ្ទះសម្រាប់អ្នកដែលមានជំងឺឆ្លង Coronavirus-2019 (COVID-19)។

**ការឱ្យនៅដាច់ពីអ្នកដទៃ៖**
អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកដែលមានឬទំនងជាមានជម្ងឺ COVID-19 (ដូចដែលបានកំណត់ខាងលើ) គឺតម្រូវឱ្យនៅដាច់ពីអ្នកដទៃនៅក្នុងផ្ទះរហូតដល់ ១៤ ថ្ងៃគិតចាប់ពីថ្ងៃចុងក្រោយដែលបុគ្គលនោះបានទាក់ទងជិតស្និទ្ធជាមួយមនុស្សដែលមានរោគសញ្ញាឬទំនងជាមានជម្ងឺ COVID-19។

**អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនរណាម្នាក់ដែលមានឬទំនងជាមានជម្ងឺ COVID-19** ត្រូវបានកំណត់ថាជាបុគ្គលដែលមានលក្ខណៈដូចខាងក្រោម៖

- រស់នៅជាមួយឬទៅលេងផ្ទះអ្នកដែលមានឬទំនងជាមានជម្ងឺ COVID-19 ជាញឹកញាប់
- គឺជាប្តីប្រពន្ធឬដៃគូជិតស្និទ្ធរបស់នរណាម្នាក់ដែលមានឬទំនងជាមានជម្ងឺ COVID-19
- គឺជាអ្នកមើលថែអ្នកដែលមានឬទំនងជាមានជម្ងឺ COVID-19
- ធ្លាប់មានទំនាក់ទំនងជាមួយអ្នកដែលមានរឺទំនងជាមានជម្ងឺ COVID-19 ខណៈពេលបុគ្គលនោះកំពុងមានរោគសញ្ញា រួមទាំងអ្នកដែល៖
    - ស្ថិតក្នុងចម្ងាយ ៦ ហ្វីតនៃនរណាម្នាក់ដែលមានឬទំនងជាមានជម្ងឺ COVID-19 ច្រើនជាង ១០ នាទីឬ
    - មានការប៉ះពាល់ដោយផ្ទាល់ដែលមិនបានការពារដល់ទឹកមាត់ឬទឹកសំបោរ (តាមរយៈការកណ្តាស់ឬក្អក) របស់អ្នកដែលមានឬទំនងជាមានជម្ងឺ COVID-19

បុគ្គលគ្រប់រូបដែលមានលក្ខណៈដូចខាងលើត្រូវតែគោរពតាមតម្រូវការដែលមានចែងក្នុងការណែនាំអំពីការឱ្យនៅដាច់ពីអ្នកដទៃដោយនៅផ្ទះសម្រាប់អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងជំងឺឆ្លង Coronavirus 2019 (COVID-19)។

បទបញ្ជាទាំងនេះគឺផ្អែកលើការកើនឡើងគួរឱ្យកត់សម្គាល់ចំពោះបុគ្គលដែលបានទទួលលទ្ធផលតេស្តវិជ្ជមានសម្រាប់ COVID-19 នៅឡុងប៊ិច។ គិតត្រឹមថ្ងៃរសៀលថ្ងៃនេះមនុស្ស ១៣៩ នាក់បានទទួលលទ្ធផលតេស្តវិជ្ជមានសម្រាប់ជម្ងឺ COVID-19 ដែលជាជំងឺផ្លូវដង្ហើមធ្ងន់ធ្ងរនៅឡុងប៊ិច។

បុគ្គលដែលមានឬទំនងជាមានជម្ងឺ COVID-19 ត្រូវបានណែនាំយ៉ាងដាច់ខាតឱ្យនៅដាច់ដោយឯងហើយបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយបុគ្គលទាំងនោះត្រូវបានស្នើសុំឱ្យនៅដាច់ពីអ្នកដទៃ។ បទបញ្ជាទាំងនេះផ្តល់នូវអំណាចនៃការអនុវត្តច្បាប់។

មន្ត្រីសុខាភិបាលអាចចាត់វិធានការបន្ថែមដែលអាចរាប់បញ្ចូលការឃុំខ្លួនជនស៊ីវិលនៅមណ្ឌលសុខភាពឬទីតាំងផ្សេងទៀតដើម្បីការពារដល់សុខភាពសាធារណៈប្រសិនបើបុគ្គលណាដែលស្ថិតក្រោមបទបញ្ជានេះរំលោភឬខកខានមិនបានអនុវត្តតាមបទបញ្ជា។ ការរំលោភបទបញ្ជានេះក៏ជាបទមជ្ឈិមដែលត្រូវផ្តន្ទាទោសដោយដាក់ពន្ធនាគារពិន័យឬទាំងពីរ។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺកូវីដ-១៩រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័ហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

###